# អនុស្សរណៈនៃកិច្ចព្រមព្រៀង

រវាង

# គម្រោង CoWES នៃ

# ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

និង

# នាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្ម

# នៃអគ្គនាយកដ្ឋានកសិកម្ម

| | |
|---|---|
| លេខសម្គាល់ | : MAFF/CoWES/2018/001-01 |
| ចំណងជើងគម្រោងសំណើរ | : បង្កើតលទ្ធផល ផ្ដល់សេវាបច្ចេកទេស សម្របសម្រួលការអនុវត្តផែនការ និង ត្រួតពិនិត្យការងារក្នុងសមាសភាគទី ១ និងទី៣ នៃគម្រោង CoWES |
| ឈ្មោះស្ថាប័នអនុវត្ត | : នាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្ម |
| អាសយដ្ឋាន | : ៥៤បេ/៤៩អេហ្វ ផ្លូវលេខ៣៩៥-៦៥៦ សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ |
| កាលបរិច្ឆេទចាប់ផ្ដើម និងបញ្ចប់ | : ថ្ងៃទី០៩ ខែ ឧសភា ឆ្នាំ ២០១៨ ដល់ថ្ងៃទី៣០ ខែ មេសា ឆ្នាំ២០២០ |

## ១. សាវតា

គម្រោង ការគ្រប់គ្រងរួមគ្នាដើម្បីការពារ និងស្តារសេវាកម្មទីជម្រាល និងប្រព័ន្ធបរិស្ថាននៅតំបន់ជួរភ្នំក្រវ៉ាញ (ប៉ែកខាងលើនៃអាងស្ទឹងព្រែកត្នោត) ឬហៅកាត់ថាៈ CoWES ត្រូវបានបង្កើតឡើង ដើម្បីកាត់បន្ថយសម្ពាធនៃការប្រើប្រាស់ដីធ្លីក្នុងតំបន់មួយចំនួន ប៉ែកខាងលើនៃអាងស្ទឹងព្រែកត្នោតតាមរយៈ ការង្ហាញឲ្យឃើញអំពីកិច្ចសហការគ្រប់គ្រងដីកសិកម្ម ការស្តារតំបន់ព្រៃឡើងវិញ រួមជាមួយនឹងកិច្ចជំរុញការគ្រប់គ្រងដីធ្លីដោយចីរភាព និងរក្សាលំនឹងមុខងាររបស់អាងរងទឹកភ្លៀង នៅតំបន់រិចរិលមួយចំនួន នៅប៉ែកខាងលើ នៃអាងស្ទឹងព្រែកត្នោត ក្នុងខេត្តកំពង់ស្ពឺ។

គម្រោងមានគោលបំណង ដើម្បីសម្រេចឲ្យបាននូវសមាសភាគចំនួន៣ គឺៈ

- ការអភិរក្សដីស្រែ និងពង្រឹងការអនុវត្តកសិ-រុក្ខកម្ម
- ការស្តារឡើងវិញ និងគ្រប់គ្រងដោយចីរភាពតំបន់ព្រៃសហគមន៍
- ការពង្រឹងសមត្ថភាពនៃការគ្រប់គ្រង និងការពិនិត្យតាមដានក្នុងតំបន់អាងស្តុកទឹក (ផ្ទៃរងទឹកភ្លៀង) នៅប៉ែកខាងលើនៃអាងស្ទឹងព្រែកត្នោត

ដើម្បីសម្រេចបានលទ្ធផលបន្ទាប់ (ឬសមាសភាគ) ទាំងបីខាងលើ គម្រោងបានដៅសកម្មភាពជាគន្លឹះមួយចំនួនដូចខាងក្រោមៈ

- ណែនាំអំពីការគ្រប់គ្រងដី និងទឹកឲ្យមានចីរភាពនៅក្នុងតំបន់
- អនុវត្តសាកល្បង កសិ-រុក្ខកម្ម នៅក្នុងតំបន់គម្រោង នៃស្រុកចំនួន២ ដើម្បីជួយបង្កើតសួនដំណាំចម្រុះ (ជ្រើសរើសពូជដំណាំ ឬរុក្ខជាតិដែលស្របនឹងស្ថានភាពដី)
- ពង្រឹងការគ្រប់គ្រងព្រៃសហគមន៍ឲ្យមានចីរភាព (ដើម្បីធ្វើជាគំរូ)
- កំណត់ និងផ្តល់ ឬជួយធ្វើឲ្យប្រសើរឡើងដល់ចីរភាពជីវភាព
- ការពង្រឹងសមត្ថភាពដល់ភាគីពាក់ព័ន្ធសំខាន់ៗ ដើម្បីការពារព្រៃឈើ និងការអនុវត្តច្បាប់
- ពិនិត្យមើល និងបង្កើតអោយមានករណីសិក្សា និងការអនុវត្តល្អទៅលើការគ្រប់គ្រងអាងស្តុកទឹក
- ផ្តល់ការគាំទ្រតាមរយៈការសិក្សាលម្អិតពីការវាយតម្លៃប្រព័ន្ធអេកូឡូស៊ីក្នុងមូលដ្ឋានដើម្បីផ្តល់ជាព័ត៌មានស្តីពីផែនការប្រើប្រាស់ដី

យោងតាមឯកសារគម្រោង (ដែលបានចុះហត្ថលេខានាថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០១៧) គម្រោង CoWES មានរយៈពេល៣ឆ្នាំដែលចាប់ផ្តើមជាផ្លូវការពីខែកក្កដា ឆ្នាំ២០១៧ ហើយបញ្ចប់ក្នុងខែ កក្កដា ឆ្នាំ២០២០។

យោងស្មារតី នៃអង្គសិក្ខាសាលាផ្តើមអនុវត្តគម្រោងនាថ្ងៃទី ១៥-១៦ ខែធ្នូ ឆ្នាំ២០១៧ (នៅសណ្ឋាគារដាយមិន ខេត្តព្រះសីហនុ) និងកិច្ចប្រជុំលើកទី១ របស់គណៈកម្មការដឹកនាំ និងតម្រង់ទិសគម្រោង ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៨ (នៅសណ្ឋាគារហូលីដេ ខេត្តកំពង់ស្ពឺ) បានកំណត់លទ្ធផលរំពឹងទុកចំនួន ៧ (ក្រោមសមាសភាគទាំង៣-Output) ដើម្បីសម្រេចឲ្យបានក្នុងអំឡុងពេល៣ឆ្នាំ នៃគម្រោង។ លទ្ធផលទាំង៧ខាងក្រោមរួមមានៈ

***<u>សមាសភាគទី ១ GEF ៖ ការអភិរក្សដីកសិកម្ម និងកសិ-រុក្ខកម្ម ត្រូវបានកែលម្អ</u>***

លទ្ធផល ទី១.១៖ អាទិភាពនៃការគ្រប់គ្រងដីដោយចីរភាព ត្រូវបានបញ្ជ្រាប ក្នុងផែនការរបស់អាជ្ញាធរមូលដ្ឋានដោយសហការជាមួយក្រសួងកសិកម្ម និងដៃគូ

លទ្ធផល ទី ១.២៖ អនុវត្តបង្ហាញអំពីការគ្រប់គ្រងដីដោយចីរភាព ដោយផ្តោតលើក្រុមកសិករមានដីតិច (ទំហំតូច)

លទ្ធផល ១.៣៖ អនុវត្តបង្ហាញអំពីការប្រើប្រាស់ដីឲ្យបានត្រឹមត្រូវ (សមស្រប) ដោយផ្តោតលើក្រុមកាន់កាប់ដីទំហំមធ្យម និងទំហំធំ (ក្រុមហ៊ុនកសិ.ឧស្សាហកម្មដែលទទួលបានសិទ្ធស្របច្បាប់)។

*សមាសភាគទី ២ ៖ តំបន់ព្រៃឈើសហគមន៍ត្រូវបានស្តារ និងគ្រប់គ្រងដោយចីរភាព*

លទ្ធផល ២.១ ៖ សកម្មភាពជាអាទិភាព ដើម្បីពន្លឿនការអនុវត្តសកម្មភាពរបស់សហគមន៍ព្រៃឈើ ត្រូវបានរំលេចក្នុងកម្មវិធីរបស់អាជ្ញាធរមូលដ្ឋាន និងកម្មវិធីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

លទ្ធផល ទី២.២ ៖ អនុវត្តបង្ហាញអំពីយុទ្ធសាស្ត្រសមស្របក្នុងការស្តារព្រៃឈើ និងការបង្កើតមុខរបរចិញ្ចឹមជីវិត

*សមាសភាគទី ៣ ៖ សមត្ថភាពគ្រប់គ្រង និងត្រួតពិនិត្យទីជម្រាលត្រូវបានបង្កើន*

លទ្ធផល ទី៣.១៖ អភិវឌ្ឍន៍សមត្ថភាពដល់ស្ថាប័នពាក់ព័ន្ធសំខាន់ៗ ដើម្បីរៀបចំ និងអនុវត្តកម្មវិធី និងសកម្មភាពរួមគ្នាក្នុងការគ្រប់គ្រងទីជម្រាល

លទ្ធផល ទី៣.២ ៖ ត្រួតពិនិត្យ និងវាយតម្លៃ ដោយមានការចូលរួម ដើម្បីគាំទ្រកម្មវិធីដែលបានព្រមព្រៀង

អនុស្សរណៈនេះ រៀបចំឡើង ដោយយោង និងអនុលោមតាមអនុសាសន៍ដែលបានផ្តល់ដោយទីប្រឹក្សាអន្តរជាតិ សិក្ខាសាលាផ្តើមអនុវត្តគម្រោង (ថ្ងៃទី១៥-១៦ ខែធ្នូ ឆ្នាំ២០១៧) និងកិច្ចប្រជុំគណៈកម្មការដឹកនាំ និងតម្រង់ទិសគម្រោង (ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៨) សំដៅពង្រឹង បង្កើនការទទួលខុសត្រូវ និងចូលរួមយ៉ាងសកម្ម នៃស្ថាប័នជំនាញរបស់រដ្ឋាភិបាល ដើម្បីធ្វើសកម្មភាព យ៉ាងពេញលេញ ដើម្បីសម្រេចបាននូវលទ្ធផលគម្រោង។ តាមរយៈអនុស្សរណៈនេះ ស្ថាប័នរដ្ឋាភិបាល នឹងដើរតួនាទីជាប្រតិបត្តិករ ទទួលកិច្ចសន្យាធ្វើសកម្មភាព បង្កើតលទ្ធផល និងផ្តល់សេវាដល់អាជ្ញាធរមូលដ្ឋាន (ឃុំ ស្រុក) សហគមន៍ ពលរដ្ឋ ព្រមទាំងជួយសម្រួលការងារជាមួយស្ថាប័នពាក់ព័ន្ធ ពិសេសមន្ទីរកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទខេត្តកំពង់ស្ពឺ នាយកដ្ឋានក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមន្ត្រី ឬទីប្រឹក្សាគម្រោង ក្នុងការគាំទ្រដល់សកម្មភាពនៅមូលដ្ឋានឲ្យទទួលបានជោគជ័យ។

អនុស្សរណៈ នេះមានវិសាលភាពស្របតាមល័ក្ខខ័ណ្ឌការងារ លទ្ធផលការងារបច្ចេកទេស និងផែនការសកម្មភាព ដែលមានភ្ជាប់ជាមួយអនុស្សរណៈ នៃកិច្ចព្រមព្រៀង ហើយមានភាពប្រទាក់ក្រឡា និងស៊ីសង្វាក់គ្នាជាមួយឯកសារក្របខ័ណ្ឌលទ្ធផល ផែនការ៣ឆ្នាំ និងផែនការប្រចាំឆ្នាំ នៃគម្រោង CoWES ។

## ២. គោលការណ៍ទូទៅ

២.១. អនុស្សរណៈនេះត្រូវបានធ្វើឡើងនៅ ថ្ងៃទី០៩ ខែ ឧសភា ឆ្នាំ ២០១៨ រវាង គម្រោង CoWES នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលបន្ទាប់ពីនេះទៅហៅកាត់ថា "ក្រសួងកិសកម្ម" និង **នាយកដ្ឋាន គ្រប់គ្រងធនធានដីកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម** ដែលបន្ទាប់ពីនេះ ទៅហៅកាត់ថា **"នាយកដ្ឋានដីកសិកម្ម"**។

២.២. អនុស្សរណៈនេះមានរយៈពេលអនុវត្តចំនួន ២៤ ខែ គិតចាប់ពីថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៨ ដល់ ថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០២០។

២.៣. អនុស្សរណៈនេះមានភ្ជាប់ជាមួយនូវល័ក្ខខ័ណ្ឌការងារ តារាងតក្កៈ លទ្ធផលគ្រោងទុក និងផែនការសកម្មភាព និងថវិកា របស់**នាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្ម** អនុលោមតាមពេលវេលាជាក់លាក់។

២.៤. **គម្រោង** នឹងវិភាជន៍ថវិកាសរុបចំនួន USD 81,562.00 (ប្រាំបីម៉ឺនមួយពាន់ប្រាំរយហុកសិបពីរដុល្លារអាមេរិកគត់) ដល់ **នាយកដ្ឋានដីកសិកម្ម** ដើម្បីអនុវត្តផែនការសកម្មភាពរបស់ខ្លួន សំដៅបង្កើតលទ្ធផល ដូចមានចែងនៅក្នុងល័ក្ខខ័ណ្ឌការងារ តារាងតក្កៈ លទ្ធផលគ្រោងទុក និងផែនការសកម្មភាពនិងថវិកា។ ការវិភាជន៍ថវិកា (ជាប្រភេទបុរេប្រទាន) នឹងអនុវត្តតាមវិធីដូចតទៅ៖

- ចំពោះសកម្មភាពចុះមូលដ្ឋាន ដើម្បីផ្តល់ការគាំទ្រដល់សហគមន៍ អ្នកពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន (នៅទីតាំងអនុវត្តគម្រោង)៖ **នាយកដ្ឋានដីកសិកម្ម** ត្រូវធ្វើសំណើចុះធ្វើសកម្មភាពប្រចាំខែ ឬប្រចាំ ត្រីមាសមកកាន់នាយក ឬប្រធានគ្រប់គ្រងគម្រោង។ **ផ្នែកគ្រប់គ្រងគម្រោង** ត្រូវរៀបចំ និងផ្តល់ប្រាក់បុរេប្រទានតាមសំណើរយៈពេលយ៉ាងយូរ ៣ថ្ងៃ (ថ្ងៃធ្វើការ) ជូនដល់ **នាយកដ្ឋានដីកសិកម្ម។ នាយកដ្ឋានដីកសិកម្ម** ត្រូវជម្រះបញ្ជីគណនេយ្យ និងបំពេញល័ក្ខខ័ណ្ឌផ្សេងៗ មុននឹងស្នើសុំថវិកាបន្ត យកទៅអនុវត្ត សកម្មភាពនាខែ ឬត្រីមាសបន្ទាប់។
- ចំពោះសកម្មភាពជាសេវាទីប្រឹក្សាបច្ចេកទេស៖ ការទូទាត់ធ្វើឡើងជាកញ្ចប់ទៅតាមលទ្ធផលការងារ ហើយការទូទាត់នេះធ្វើឡើងជាបីដំណាក់កាល៖ **ដំណាក់កាលទី ១** នឹងផ្តល់ជូន ៤០% ដល់ទីប្រឹក្សា (ទទួលបានការងារ) បន្ទាប់ពីចុះកិច្ចសន្យា **ដំណាក់កាលទី ២** ផ្តល់ជូន ៤០% បន្ថែម នៅពេលទីប្រឹក្សារៀបចំសេចក្តីព្រាងឯកសារ (មេរៀនបណ្តុះបណ្តាល លទ្ធផលសិក្សាបច្ចេកទេស យុទ្ធសាស្ត្រ ឬអនុសាសន៍ របាយការណ៍។ល។) និង**ដំណាក់កាលទី៣** ផ្តល់ជូន ២០% (ចុងក្រោយ) នៅពេលទទួលបានឯកសារ និងរបាយការណ៍បញ្ចប់ការងារ ក្រោយពេលពិនិត្យវាយតម្លៃដោយនាយកដ្ឋានដីកសិកម្ម និងអនុលោមភាពដោយនាយក ឬប្រធានគម្រោង ។
- បន្ទាប់ពីមានការយល់ព្រមពីនាយកដ្ឋានដីកសិកម្ម និងនាយកគម្រោង ឬប្រធានគ្រប់គ្រងគម្រោង នាយកដ្ឋានដីកសិកម្ម ត្រូវធ្វើសំណើទូទាត់ថវិកាដល់ទីប្រឹក្សាដែលបានបំពេញការងារ ហើយថវិកានឹងទូទាត់ជាវិក័យបត្រដោយរដ្ឋបាលគម្រោងជូនដល់ទីប្រឹក្សា។

២.៥. ក្នុងអំឡុងពេលអនុវត្តសកម្មភាពក្រោមកិច្ចសន្យាបន្ត ជាមួយគម្រោងនេះ បុគ្គលិក ឬស្ថាប័នទទួលកិច្ចសន្យាបន្តទាំងនេះ មិនត្រូវចាត់ជាបុគ្គលិក ឬស្ថាប័ន របស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិឡើយ ដូច្នេះកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិមិនទទួលខុសត្រូវចំពោះគ្រោះថ្នាក់ សុវត្ថិភាព ការងារ សន្តិសុខ ឬទូទាត់លើសំណងដែលទាមទារដោយបុគ្គលិក ឬអង្គភាពទាំងនេះឡើយ ដែលអ្វីទាំងអស់នេះ គឺស្ថិតនៅក្រោមការទទួលខុសត្រូវ និងបន្ទុកផ្ទាល់របស់ **នាយកដ្ឋានដីកសិកម្ម**។

២.៥. **នាយកដ្ឋានដីកសិកម្ម** (ទាំងបុគ្គល ឬស្ថាប័នដែលទទួលកិច្ចសន្យាបន្ត) ត្រូវមានគណនេយ្យភាព និងការទទួលខុសត្រូវ ចំពោះមុខជាមួយគម្រោង CoWES នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ៣. អំពីការគ្រប់គ្រងហិរញ្ញវត្ថុ និងការប្រើប្រាស់

៣.១. **នាយកដ្ឋានដីកសិកម្ម** ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រង និងប្រើប្រាស់ថវិកាឲ្យបានត្រឹមត្រូវ ដោយធានាឲ្យបាននូវគណនេយ្យភាព តម្លាភាព និងប្រសិទ្ធភាពខ្ពស់ ។

៣.២. គោលនយោបាយគ្រប់គ្រង និងប្រតិបត្តិការរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គ.ជ.អ.ប (NCDD) នឹងត្រូវយកមកអនុវត្តនៅក្នុងការប្រើប្រាស់មូលនិធិដែលបានផ្តល់នេះ។

៣.៣. ដើម្បីជំរុញដល់ការអនុវត្តសកម្មភាព និងការប្រើប្រាស់ថវិកាឲ្យបានត្រឹមត្រូវ **ក្រុមការងារគម្រោង** នឹងផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់ **នាយកដ្ឋានដីកសិកម្ម** តាមរយៈមន្ត្រីគាំទ្រគម្រោង និងទីប្រឹក្សាគម្រោង តាមតម្រូវការជាក់ស្តែង។

៣.៤. រាល់ការប្រើប្រាស់មូលនិធិរបស់គម្រោង **នាយកដ្ឋានដីកសិកម្ម** ត្រូវធានាថា មូលនិធិនេះត្រូវបានប្រើប្រាស់ចំទិសដៅ ដូចមានចែងក្នុងល័ក្ខខ័ណ្ឌការងារ តារាងតក្កៈ លទ្ធផលគ្រោងទុក និងផែនការសកម្មភាពនិងថវិកាដែលភ្ជាប់ជាមួយអនុស្សរណៈនេះ។

៣.៥. **នាយកដ្ឋានដីកសិកម្ម** ត្រូវធានាថា មូលនិធិនេះមិនមែនជាកម្មវត្ថុនៃការប្រើប្រាស់សម្រាប់ជាប្រយោជន៍បុគ្គល មានដូចជា ការខ្ចីផ្ទាល់ខ្លួន ការយកមូលនិធិសម្រាប់ចងការប្រាក់ ឬការបុរេប្រទានសម្រាប់សកម្មភាពផ្សេងក្រៅពីសកម្មភាពដែលបានកំណត់ក្នុងផែនការសកម្មភាពនិងថវិកាក្នុងឯកសារគម្រោងឡើយ។

## ៤. ការទទួលខុសត្រូវរបស់គម្រោង CoWES នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

៤.១. **គម្រោង** ត្រូវផ្ទេរមូលនិធិជាលក្ខណៈបុរេប្រទានជូនទៅ **នាយកដ្ឋានដីកសិកម្ម** ផ្អែកតាមសំណើរបស់ **នាយកដ្ឋានដីកសិកម្ម** ឬទូទាត់ជាកញ្ចប់តាមលទ្ធផលជាក់ស្តែងដែល **នាយកដ្ឋានដីកសិកម្ម** សម្រេចបាន (មានការវាយតម្លៃដោយនាយកដ្ឋានដីកសិកម្ម និងឯកភាពលើលទ្ធផលដោយប្រធានគម្រោង) ។

៤.២. ផ្តល់រាល់ទម្រង់បែបបទ នីតិវិធី ប្រព័ន្ធគាំទ្រ ជំនួយបច្ចេកទេស និងការអភិវឌ្ឍសមត្ថភាព ដែលត្រូវការចាំបាច់សម្រាប់ការរៀបចំតាក់តែង ការកសាងផែនការ ការតាមដាន ត្រួតពិនិត្យ និងការរៀបចំរបាយការណ៍ របស់ **នាយកដ្ឋានដីកសិកម្ម**។

៤.៣. តាមដានត្រួតពិនិត្យការអនុវត្តសកម្មភាព ការសម្រេចនូវលទ្ធផល ការផ្តល់សេវាបច្ចេកទេស និងល័ក្ខខ័ណ្ឌការងារដើម្បីធានាឱ្យមានភាពសមស្របជាមួយនឹងគម្រោង CoWES និងអនុស្សរណៈនេះ។

៤.៤. ធ្វើការសិក្សា និងវាយតម្លៃការអនុវត្តសកម្មភាព ជាទៀងទាត់ ដែលក្នុងនោះ រួមទាំងការស្នើសុំឱ្យមានការផ្តល់យោបល់ពីស្ថាប័នអនុវត្តនានា ក្នុងគោលបំណងសិក្សារៀនសូត្រអំពីចំណុចខ្លាំង និងចំណុចខ្សោយនៃកិច្ចដំណើរការអនុវត្តគម្រោង ។

## ៥. ការទទួលខុសត្រូវរបស់នាយកដ្ឋានដីកសិកម្ម

៥.១. **នាយកដ្ឋានដីកសិកម្ម** ត្រូវមានគណនេយ្យភាពចំពោះ **គម្រោង** CoWES និង **ម្ចាស់ជំនួយ** (UNDP/GEF) ក្នុងការអនុវត្តសកម្មភាពដែលបានចែងលម្អិតក្នុងល័ក្ខខ័ណ្ឌការងារ តារាងតក្កៈ និងផែនការសកម្មភាព និងថវិកា ។

៥.២. **នាយកដ្ឋានដីកសិកម្ម** ត្រូវអនុវត្តតាមគោលការណ៍ណែនាំនានាដែលបានផ្តល់ជូន និងត្រៀមផ្តល់ជូននាពេលខាងមុខនូវរបាយការណ៍វឌ្ឍនភាព និងការចំណាយរៀងរាល់ខែ ដល់ផ្នែកគ្រប់គ្រងគម្រោង។

៥.៣. រៀបចំផែនការសកម្មភាព ថវិកា ឬសំណើសុំបុរេប្រទានថវិកា ដើម្បីអនុវត្តសកម្មភាព មកកាន់គម្រោង CoWES។

៥.៤. រៀបចំរបាយការណ៍វឌ្ឍនភាព របាយការណ៍បេសកកម្ម និងជម្រះប្រាក់បុរេប្រទានជាមួយផ្នែកគ្រប់គ្រងគម្រោង មុននឹងស្នើសុំប្រាក់បុរេប្រទានយកទៅអនុវត្តសកម្មភាពបនាពេលបន្ទាប់ ។

៥.៥. ផ្តល់ព័ត៌មានដល់ **គម្រោង** ជាប្រចាំ ក្នុងពេលដែលការអនុវត្តណាមួយមិនអាចសម្រេចបានតាមការគ្រោងទុក និងក្នុងពេលដែលយល់ឃើញថា សកម្មភាព ឬលទ្ធផលណាមួយមិនអាចសម្រេចបានតាមគោលបំណង ឬលទ្ធផលរំពឹងទុក។

៥.៦. ធ្វើរបាយការណ៍ឲ្យបានត្រឹមត្រូវ និងមានព័ត៌មានយ៉ាងពេញលេញ និងទាន់ពេល ព្រមទាំងប្រើប្រាស់នូវប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រង តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ លើសកម្មភាពដែលបានអនុវត្តដើម្បីរៀបចំចងក្រងរក្សាទុកព័ត៌មានទាំងនោះឲ្យបានល្អ និងមានសុវត្ថិភាពខ្ពស់។

៥.៧. ថវិកាដែលនៅសល់ពីការប្រើប្រាស់ ត្រូវតែបង្វែរត្រឡប់មក **គម្រោង** វិញនៅពេលបញ្ចប់ការអនុវត្តសកម្មភាព ឬនៅពេលគម្រោងត្រូវបានបញ្ចប់ជាស្ថាពរ ឬការស្នើឲ្យបង្វិលថវិកាត្រឡប់ក្នុងករណីចាំបាច់ណាមួយ។

៥.៨. រៀបចំបូកសរុប ចងក្រង ប្រមូលផ្តុំឯកសារ ឬព័ត៌មាន កសាងបទពិសោធន៍ល្អៗ និងផ្តល់លទ្ធភាពគ្រប់ពេលវេលាក្នុងការឆ្លើយតបដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរចំពោះការស្នើសុំរបស់ **គម្រោង** ពាក់ព័ន្ធទៅនឹងការអនុវត្តអនុស្សរណៈនេះ។

៥.៩. សហការយ៉ាងជិតស្និតជាមួយស្ថាប័នរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល សកលវិទ្យាល័យ ពិសេសរដ្ឋបាលព្រៃឈើ (គម្រោងទីជម្រាលស្ទឹងព្រែកត្នោត) ដើម្បីអនុវត្ត និងបង្កើតបានជាលទ្ធផលក្នុងសមាសភាគទី៣ ក្រោមគម្រោង CoWES នេះ។

៥.៩. ជាសេនាធិការរបស់ប្រធាន និងនាយកគម្រោងក្នុងការជ្រើសរើសទីប្រឹក្សាបច្ចេកទេស (មានក្នុងល័ក្ខខ័ណ្ឌការងារ ឬតារាងតក្ក:) វាយតម្លៃលើគុណភាព និងលទ្ធផលការងាររបស់ទីប្រឹក្សាជាតិ ផ្តល់បច្ចេកទេស ផ្តល់ការបណ្តុះបណ្តាលដល់សហគមន៍ និងជួយជំរុញការអនុវត្តគម្រោងឲ្យមានប្រសិទ្ធភាពខ្ពស់។

## ៦. ការមិនអនុវត្តតាមល័ក្ខខ័ណ្ឌនៃអនុស្សរណៈ

ក្នុងករណី **នាយកដ្ឋានដីកសិកម្ម** មិនអនុវត្តតាមល័ក្ខខ័ណ្ឌនៃអនុស្សរណៈនេះ **គម្រោង**មានសិទ្ធិប្រកាន់យកនូវវិធានការដូចខាងក្រោម៖

៦.១. តម្រូវឱ្យ **នាយកដ្ឋានដីកសិកម្ម** ផ្ទេរនូវមូលនិធិមួយចំនួន ឬទាំងអស់ត្រឡប់មក **គម្រោង** វិញ។

៦.២. ប្រកាន់យកនូវដំណើរការដាក់ពិន័យនានាតាមច្បាប់ចំពោះបុគ្គល ដែលរកឃើញថា បានរំលោភបំពានទៅលើនីតិវិធីដែលបានកំណត់ ដើម្បីជាប្រយោជន៍ផ្ទាល់ខ្លួន។

## ៧. ការធ្វើវិសោធនកម្មអនុស្សរណៈ

៧.១. អនុស្សរណៈនេះអាចធ្វើការកែប្រែបានតាមការចាំបាច់ដរាបណាមានការព្រមព្រៀង និងការទទួលស្គាល់ជាលាយលក្ខណ៍អក្សរពី **គម្រោង** និង **នាយកដ្ឋានដីកសិកម្ម** ប៉ុន្តែការកែប្រែនេះមិនត្រូវផ្ទុយទៅនឹងឯកសារគម្រោងស្តីពី "ការគ្រប់គ្រងរួមគ្នា ដើម្បីការពារ និងស្តារសេវាកម្មទីជម្រាល និងប្រព័ន្ធបរិស្ថាននៅតំបន់ជួរភ្នំក្រវាញ (ប៉ែកខាងលើនៃអាងស្ទឹងព្រែកត្នោត)"។ ក្នុងករណីមានការធ្វើវិសោធនកម្ម **នាយកដ្ឋានដីកសិកម្ម** ត្រូវរៀបចំឯកសារដូចខាងក្រោម ៖

-លិខិតស្នើសុំធ្វើវិសោធនកម្មមក **គម្រោង**

-បំពេញទម្រង់ផែនការសកម្មភាព និងថវិកាដែលបញ្ជាក់អំពីការប្រែប្រួលនេះ។

## ៨. ការចុះហត្ថលេខាលើអនុស្សរណៈ

អ្នកចុះហត្ថលេខាខាងក្រោមនេះ ជាតំណាងពេញសិទ្ធិរបស់គម្រោង និង នាយកដ្ឋានដីកសិកម្ម ដែលបានព្រមព្រៀងទៅលើល័ក្ខខ័ណ្ឌនានាដូចបានចែងក្នុងអនុស្សរណៈនេះ។

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

(គម្រោង CoWES)

**ឈ្មោះ ៖ បណ្ឌិត មាស ពិសិដ្ឋ**

**មុខងារ ៖** អគ្គលេខាធិការរង និងជាប្រធានគ្រប់គ្រងគម្រោង

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**នាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្ម**

**ឈ្មោះ ៖ បណ្ឌិត កុយ រ៉ា**

**មុខងារ ៖** ប្រធាននាយកដ្ឋាន

**នាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្ម**